**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៤ សរ

# សារាចរ

## ស្តីពី

## ការដាក់ចេញយុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

កន្លងទៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាជន។ បន្ថែមលើវិធានការបង្ការ, ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញ និងកំពុងអនុវត្តយ៉ាងសកម្មនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំង ដែលត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រគន្លឹះ និងជាខ្សែក្រវាត់ការពារសំខាន់ជាងគេ ដើម្បីបង្កើតឱ្យមានភាពស៊ាំក្នុងសហគមន៍ទប់ទល់នឹងមេរោគកូវីដ-១៩ សំដៅការពារសុខភាពនិងអាយុជីវិតរបស់ប្រជាជន ក៏ដូចជាដើម្បីឈានឆ្ពោះទៅបើកដំណើរការប្រទេសជាតិឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយនឹងជំងឺនេះតាមគន្លងប្រក្រតីភាពថ្មី។

ទោះបីជាមកដល់ពេលនេះស្ថានភាពនៃជំងឺកូវីដ-១៩ ពុំទាន់ឈានដល់ការឆ្លងរាលដាលទ្រង់ទ្រាយធំក្នុងសហគមន៍យ៉ាងណាក្តី ប៉ុន្តែ ការឆ្លងរាលដាលនៅមិនទាន់បានថមថយ និងនៅតែបន្តកើនឡើងក្នុងកម្រិតមួយសកម្ម ដែលជាបញ្ហាប្រឈមដ៏គួរឱ្យបារម្ភ។ ទន្ទឹមនេះ ព្រះរាជាណាចក្រកម្ពុជាក៏បានរកឃើញជាបន្តបន្ទាប់នូវវត្តមានមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) ដែលជាករណីនាំចូលតាមរយៈអ្នកដំណើរពីក្រៅប្រទេសជាពិសេស អ្នកដំណើរមកពីប្រទេសថៃតាមព្រំដែនគោក។ ក្នុងរយៈពេលចុងក្រោយនេះ ការរកឃើញក្នុងចំនួនកាន់តែច្រើនឡើងនៃមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) លើពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ តាមព្រំដែនគោក គឺជាកង្វល់ដ៏ធំ និងជាការគំរាមកំហែងជាប់ជាប្រចាំដល់ព្រះរាជាណាចក្រកម្ពុជាដោយសារមេរោគប្រភេទថ្មីនេះ មានកម្រិតនៃការឆ្លងរាលដាលលឿន និងកម្រិតគ្រោះថ្នាក់ធ្ងន់ធ្ងរជាងមុន ហើយហានិភ័យបានឈានដល់កម្រិតខ្ពស់គួរឱ្យបារម្ភ ជាមួយនឹងការរកឃើញមេរោគប្រភេទថ្មីនេះជាលើកដំបូងក្នុងសហគមន៍ ជាពិសេស នៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ ព្រមទាំងខេត្តសៀមរាប និងខេត្តកំពង់ធំ។

ចំពោះមុខស្ថានភាពដែលកំពុងវិវត្តយ៉ាងលឿនគួរឱ្យបារម្ភនេះ និងក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជាពុំទាន់សម្រេចបានដោយជោគជ័យក្នុងការបង្កើតឱ្យមានពេញលេញនូវ **"ភាពស៊ាំក្នុងសហគមន៍"** សម្រាប់ប្រជាជនកម្ពុជានៅទូទាំងប្រទេស ដោយសារយុទ្ធនាការជាតិចាក់វ៉ាក់សាំងពុំទាន់ត្រូវបានបញ្ចប់នៅឡើយ,

វិធានការបង្ការ និងទប់ស្កាត់ ត្រូវបានចាត់ទុកជាវិធានការអាទិភាព និងជាគន្លឹះដ៏សំខាន់ ក្នុងការកាត់បន្ថយអត្រានៃការឆ្លងរាលដាល ព្រមទាំងអត្រាមរណភាពដែលបណ្តាលមកពីជំងឺនេះ ក៏ដូចជាក្នុងការទប់ស្កាត់រលកទី៣នៃការឆ្លងរាលដាលទ្រង់ទ្រាយធំនៃជំងឺនេះ ដែលបណ្តាលមកពីមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) ក្នុងសហគមន៍។ ជាការពិត ការចូលរួមប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីសំណាក់ប្រជាពលរដ្ឋគ្រប់ៗរូប, គ្រួសារនីមួយៗ, សហគមន៍ និងពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ទាំងផ្នែកឯកជន និងផ្នែកសាធារណៈ ក្នុងការអនុវត្តវិធានការសុវត្ថិភាពឱ្យបានខ្ជាប់ខ្ជួន និងឱ្យបានត្រឹមត្រូវ ដើម្បីការពារខ្លួនពីជំងឺនេះ គឺជាកត្តាសំខាន់ជាងគេក្នុងការអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺនេះ។ កន្លងមក ក្រសួងសុខាភិបាលបានធ្វើការផ្សព្វផ្សាយ ក៏ដូចជាអប់រំ, ពន្យល់ និងណែនាំយ៉ាងទូលំទូលាយច្រើនលើកច្រើនសា ជាបន្តបន្ទាប់ជូនប្រជាពលរដ្ឋឱ្យយល់ដឹងអំពីគ្រោះថ្នាក់ធ្ងន់ធ្ងរនៃជំងឺនេះចំពោះអាយុជីវិតប្រជាជន និងប្រទេសជាតិ ព្រមទាំងអំពីវិធីការពារខ្លួនឱ្យបានត្រឹមត្រូវ ដើម្បីបង្ការពីការឆ្លងនៃជំងឺនេះ។ ទោះជាយ៉ាងនេះក្តី ប្រជាពលរដ្ឋមួយចំនួននៅតែមានការធ្វេសប្រហែស មិនបានអនុវត្តឱ្យខ្ជាប់ខ្ជួន និងឱ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងសុខាភិបាលនៅឡើយ។

ដូចនេះ ការពង្រឹងវិធានការទាំងផ្នែករដ្ឋបាល ទាំងផ្នែកសុវត្ថិភាពសុខាភិបាល ទាំងផ្នែកផ្លូវច្បាប់ គឺជាកត្តាសំខាន់ដ៏ចាំបាច់ បន្ថែមពីលើវិធានការអប់រំ និងណែនាំនានាកន្លងមក ដែលមិនត្រឹមតែអាចកាត់បន្ថយបាននូវការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បច្ចុប្បន្ននេះប៉ុណ្ណោះទេ ថែមទាំងបង្កើតបាននូវលក្ខណៈសម្បត្តិ ដើម្បីឈានឆ្ពោះទៅការអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់ការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីបន្ទាប់ពីយុទ្ធនាការនៃការចាក់វ៉ាក់សាំងនឹងត្រូវបញ្ចប់ដោយជោគជ័យនាពេលខាងមុខនេះ។

ក្នុងន័យនេះ ដើម្បីធានាបានប្រសិទ្ធភាពនៃការអនុវត្តវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេស ក្នុងបរិបទដែលកម្ពុជាកំពុងប្រឈមនឹងការមកដល់នៃរលកទី៣ នៃការឆ្លងរាលដាលទ្រង់ទ្រាយធំនៃជំងឺកូវីដ-១៩ បណ្តាលមកពីមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta), **រាជរដ្ឋាភិបាល** សម្រេចដាក់ចេញនូវ **"យុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩"** នៅទូទាំងប្រទេស សម្រាប់រយៈពេល **១៤ (ដប់បួន) ថ្ងៃ គិតចាប់ពីវេលាម៉ោង ២៣:៥៩ នាទី (ម្ភៃបីនិងហាសិបប្រាំបួននាទី) នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១** និងដាក់ចេញនូវវិធានការចាំបាច់មួយចំនួន ដែលត្រូវអនុវត្តជាបន្ទាន់ក្នុងយុទ្ធនាការនេះ ដូចតទៅ៖

ទី១-គណៈអភិបាលរាជធានី-ខេត្តទាំងអស់ ត្រូវដាក់ចេញនូវវិធានការរដ្ឋបាល និងវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ព្រមទាំងពង្រឹងការអនុវត្តវិធានការច្បាប់ នៅក្នុងភូមិសាស្ត្ររបស់ខ្លួនឱ្យបានព្រមៗពេលជាមួយគ្នា និងត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់និងតឹងរ៉ឹង នៅក្នុងអំឡុងពេលអនុវត្តយុទ្ធនាការនេះ។

ទី២-ក្នុងរយៈពេលនៃការអនុវត្តយុទ្ធនាការនេះ គណៈអភិបាលរាជធានី-ខេត្ត ត្រូវដាក់ចេញវិធានការចាំបាច់មួយចំនួន ដូចខាងក្រោម៖

- ហាមឃាត់ការធ្វើសកម្មភាព មុខរបរ និងអាជីវកម្មក្លឹបកម្សាន្តគ្រប់ប្រភេទ ជាអាទិ៍ ខារ៉ាអូខេ, វង្គសាល, ឌីស្កូតែក និងបៀហ្គាឌិន, រមណីយដ្ឋាន និងសួនកម្សាន្តនានា, អាជីវកម្មម៉ាស្សា, ហាងលក់និងសេពគ្រឿងស្រវឹងគ្រប់ប្រភេទ, រោងភាពយន្ត, រោងសម្តែងសិល្បៈ, សារមន្ទីរ, ក្លឹបហាត់ប្រាណ និងមជ្ឈមណ្ឌលកីឡា។ អាជ្ញាធរអាចសម្រេចហាមឃាត់សកម្មភាពការងារ មុខរបរ និងអាជីវកម្មផ្សេងទៀត ដោយយោងតាមតម្រូវការចាំបាច់ក្នុងការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។
- រាល់ការជួបជុំ ឬការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជនដែលមានមនុស្សចូលរួមលើសពី ១០ (ដប់) នាក់ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច លើកលែងតែការជួបជុំក្នុងចំណោមសមាជិកគ្រួសារ ដែលរស់នៅក្នុងលំនៅឋាន ឬទីសំណាក់ជាមួយគ្នា, ការរៀបចំពិធីបុណ្យសពដោយគោរពតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច, ការជួបជុំរបស់ស្ថាប័នសាធារណៈ, ការប្រមូលផ្តុំមនុស្ស និងការជួបជុំរបស់បុគ្គលិកសុខាភិបាលដើម្បីអនុវត្តវិធានការសុខាភិបាល ជាអាទិ៍ ការយកវត្ថុសំណាកមកវិភាគរកមេរោគកូវីដ-១៩ និងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩, ការជួបជុំរបស់បុគ្គលិកសុខាភិបាលដែលបំពេញការងារសង្គ្រោះបន្ទាន់ផ្សេងទៀត និងការជួបជុំរបស់អាជ្ញាធរមានសមត្ថកិច្ច និងកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ក្នុងការបំពេញការងារថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ, ការជួបជុំមនុស្សក្នុងអំឡុងពេលនៃកិច្ចនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬរបស់សាលាជម្រះក្តី និងការជួបជុំមនុស្សដែលមានភាពចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬក្នុងគោលបំណងផ្សេងទៀតតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច។
- ហាមឃាត់រាល់ការជួបជុំ ឬការប្រមូលផ្តុំមនុស្សដើម្បីសេពគ្រឿងស្រវឹងគ្រប់ប្រភេទ។
- ភោជនីយដ្ឋាន-អាហារដ្ឋាន អនុញ្ញាតឱ្យប្រកបអាជីវកម្មរបស់ខ្លួនត្រឹមជាលក្ខណៈវេចខ្ចប់ប៉ុណ្ណោះ ដោយមិនត្រូវអនុញ្ញាតឱ្យអតិថិជនចូលមកទទួលទាននៅក្នុងបរិវេណនៃទីកន្លែងរបស់ខ្លួនឡើយ លើកលែងតែភោជនីយដ្ឋាន-អាហារដ្ឋាន ដែលអាចធានាបាននូវវិធានសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេស ការរក្សាបាននូវគម្លាតសុវត្ថិភាពបុគ្គល និងសង្គម។
- ដាក់ចេញបម្រាមគោចរពីចន្លោះម៉ោង ២១ (ម្ភៃមួយ) ដល់ម៉ោង ៣ (បី) សម្រាប់ភូមិសាស្ត្រទាំងមូល ឬផ្នែកណាមួយដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ជាពិសេស សម្រាប់រាជធានីភ្នំពេញ ទីរួមខេត្ត និងទីប្រជុំជននានា។ ក្នុងការអនុវត្តបម្រាមគោចរនេះ គណៈអភិបាលរាជធានី-ខេត្ត ត្រូវយកចិត្តទុកដាក់ធានាឱ្យបាននូវការធ្វើដំណើរ និងការធ្វើសកម្មភាពការងារចាំបាច់មួយចំនួន ជាអាទិ៍ ការធ្វើដំណើររបស់មន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ, ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់, ការដឹកជញ្ជូនទំនិញ និងគ្រឿងឧបភោគបរិភោគ, ការដឹកជញ្ជូនទំនិញយុទ្ធសាស្ត្ររបស់រដ្ឋ, សេវាសង្គ្រោះបន្ទាន់ និងសេវាសុខាភិបាលទាំងរដ្ឋ និងឯកជន, ឱសថស្ថាន, សេវាពន្លត់អគ្គិភ័យ, សេវាផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត, សេវាប្រតិបត្តិការផ្នែកទូរគមនាគមន៍, ទីតាំងផលិត

គ្រឿងឧបភោគបរិភោគ និងទំនិញយុទ្ធសាស្ត្រដែលបម្រើឱ្យការប្រយុទ្ធនិងទប់ស្កាត់ជំងឺកូវីដ-១៩, ទីតាំងផលិតនិងផ្គត់ផ្គង់ឱសថ អាល់កុល អុកស៊ីហ្សែន និងសម្ភារៈបរិក្ខារវេជ្ជសាស្ត្រផ្សេងទៀត, ស្ថានីយ៍ប្រេងឥន្ធនៈ-ហ្គាស, សេវាសណ្ឋាគារ និងផ្ទះសំណាក់, ការបំពេញកាតព្វកិច្ចដែលបម្រើផលប្រយោជន៍សាធារណៈ និងករណីចាំបាច់ ឬសេវាសាធារណៈចាំបាច់ដទៃទៀត។

- រាល់សកម្មភាពនៃការជួបជុំ ឬការប្រមូលផ្តុំមនុស្ស , សកម្មភាពការងារ មុខរបរ និងអាជីវកម្មដែលត្រូវបានអនុញ្ញាត ត្រូវអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលឱ្យបានម៉ឺងម៉ាត់ ជាអាទិ៍ កាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពបុគ្គល និងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការវាស់កម្តៅ និងការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលផ្សេងទៀត។

ទី៣-ក្នុងរយៈពេលនៃការអនុវត្តយុទ្ធនាការនេះ គណៈអភិបាលរាជធានី-ខេត្ត ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការដាក់ចេញការហាមឃាត់ ឬរឹតបន្តឹងការត្រួតពិនិត្យ និងការរៀបចំរបៀបរៀបរយ និងសណ្តាប់ធ្នាប់នៅតាមទីកន្លែងដែលជាប្រភព ឬអាចមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសផ្សារ និងទីកន្លែងលក់ដូរគ្រឿងឧបភោគបរិភោគ និងទីតាំងអាជីវកម្មផ្សេងទៀត ព្រមទាំងទីតាំងរៀបចំកម្មវិធីសាសនា កម្មវិធីប្រពៃណី កម្មវិធីកីឡា ឬកម្មវិធីកំសាន្តនានា, និងត្រូវហាមឃាត់មិនឱ្យបើកដំណើរការចំពោះផ្សារ ឬទីតាំងណាដែលមិនរៀបរយ ឬដែលមិនធានាបាននូវវិធានការសុវត្ថិភាពផ្នែកសុខាភិបាល។

ទី៤-គណៈអភិបាលរាជធានី-ខេត្ត ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការចាត់វិធានការចាំបាច់នានាក្នុងភូមិសាស្ត្រដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យបាននូវការគោរព និងអនុវត្តនូវវិធានការសុខាភិបាលនានា ដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេស កាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ព្រមទាំងប្រកាន់ខ្ជាប់នូវវិធានការ **"៣ការពារ និង ៣កុំ"** នៅតាមទីតាំងសាធារណៈនានា ជាពិសេស នៅតាមផ្សារ, ទីកន្លែងលក់ទំនិញដែលមិនរៀបរយ, វត្តអារាម, វិហារសាសនា និងទីតាំងផ្សេងទៀតដែលមានសភាពអ៊ូអរ និងមានមនុស្សជួបជុំគ្នាក្នុងចំនួនច្រើន។ ទន្ទឹមនេះ គណៈអភិបាលរាជធានី-ខេត្ត ត្រូវយកចិត្តទុកដាក់អប់រំណែនាំគ្រឹះស្ថានសាធារណៈ និងឯកជន, ម្ចាស់អាជីវកម្ម, ម្ចាស់ភោជនីយដ្ឋាន-អាហារដ្ឋាន និងម្ចាស់ទីតាំងដែលមានការជួបជុំ ឬប្រមូលផ្តុំមនុស្សច្រើន ក៏ដូចជាប្រជាពលរដ្ឋឱ្យប្រើប្រាស់ប្រព័ន្ធ QR Code **"ទប់ស្កាត់កូវីដ"** ( Stop Covid )។

ទី៥-គណៈអភិបាលរាជធានី-ខេត្ត ត្រូវយកចិត្តទុកដាក់ក្នុងការដាក់ចេញវិធានការចាំបាច់ និងសមស្របនានាឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា ដោយផ្អែកតាមកម្រិតនៃការឆ្លងរាលដាលទ្រង់ទ្រាយធំនៃជំងឺកូវីដ-១៩ ក្នុងភូមិសាស្ត្រដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន សំដៅគ្រប់គ្រងកន្លែងដែលមានការផ្ទុះឆ្លង និងកាត់ផ្តាច់ការឆ្លងរាលដាលនៃជំងឺនេះ ទាំងនៅក្នុងភូមិសាស្ត្រដែលត្រូវបិទខ្ទប់ និងទៅតំបន់ផ្សេងទៀត តាមរយៈអភិក្រមនៃការគ្រប់គ្រងដោយបែងចែកជា **"តំបន់ក្រហម"** សម្រាប់ភូមិសាស្ត្រដែលមានកម្រិតនៃការឆ្លងរាលដាលធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ **និង/ឬ "តំបន់លឿងទុំ"** សម្រាប់ភូមិសាស្ត្រដែលមានកម្រិតនៃការឆ្លង

រាលដាលមធ្យមនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ **និង/ឬ "តំបន់លឿង"** សម្រាប់ភូមិសាស្ត្រដែលមានកម្រិតនៃការឆ្លងរាលដាលស្រាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍។

ទី៦-ក្នុងករណីរកឃើញថាមានការឆ្លងរាលដាលនៃមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) នៅក្នុងសហគមន៍ គណៈអភិបាលរាជធានី-ខេត្ត ត្រូវដាក់ចេញនូវវិធានការឆ្លើយតបជាបន្ទាន់ សំដៅគ្រប់គ្រងតំបន់ដែលមានការផ្ទុះឆ្លងឱ្យបានទាន់ពេលវេលា និងកាត់ផ្តាច់កុំឱ្យឆ្លងទៅតំបន់ផ្សេងទៀត ក្នុងការបិទខ្ទប់ទីកន្លែង តំបន់ ឬភូមិសាស្ត្រដែលមានការផ្ទុះឆ្លង ព្រមទាំងត្រូវធ្វើការស្រាវជ្រាវរកអ្នកពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោលជាមួយអ្នកមានផ្ទុកមេរោគប្រភេទថ្មីនេះ សំដៅកាត់ផ្តាច់ឱ្យបានទាន់ពេលវេលានូវខ្សែច្រវាក់នៃការចម្លងមេរោគប្រភេទថ្មីនេះ ទៅទីកន្លែង ឬតំបន់ផ្សេងទៀត។ គណៈអភិបាលរាជធានី-ខេត្ត ជាពិសេសបណ្តាគណៈអភិបាលខេត្តជាប់ព្រំដែន ត្រូវចាត់ទុកការទប់ស្កាត់ ឬកាត់ផ្តាច់ការឆ្លងរាលដាលនូវមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) នៅក្នុងសហគមន៍ ជាអាទិភាពចម្បង និងជាការទទួលខុសត្រូវខ្ពស់បំផុតរបស់ខ្លួន ដែលការដាក់ចេញវិធានការនានា ត្រូវតែមានភាពម៉ឺងម៉ាត់ និងឆាប់រហ័ស។

ទី៧-អនុគណៈកម្មការដឹកនាំការអនុវត្តច្បាប់ ចំណុះឱ្យគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៨០ សសរ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ ដោយសហការជាមួយអនុគណៈកម្មការដែលមានការពាក់ព័ន្ធ និងគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ត្រូវដឹកនាំ សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តវិធានការបង្ការ និងទប់ស្កាត់ខាងលើនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ និងអាចដាក់ចេញវិធានការចាំបាច់ដទៃទៀត ស្របតាមសេចក្តីណែនាំលេខ ០៣ សណន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត សំដៅធានាឱ្យយុទ្ធនាការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺនេះនៅទូទាំងប្រទេស ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងភាពជោគជ័យ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយឱ្យបានជាអតិបរមានូវអត្រានៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ទី៨-គណៈអភិបាលរាជធានី-ខេត្ត ត្រូវរៀបចំបន្ថែមនូវគោលដៅសាធារណៈសម្រាប់ការធ្វើតេស្តរហ័សរកមេរោគកូវីដ-១៩ ក្នុងភូមិសាស្ត្ររបស់ខ្លួន ដើម្បីបម្រើឱ្យសាធារណជនដោយឥតគិតថ្លៃ។ អនុគណៈកម្មការផ្គត់ផ្គង់ និងហិរញ្ញវត្ថុ ត្រូវធានាផ្គត់ផ្គង់ឧបករណ៍តេស្តរហ័សរកមេរោគកូវីដ-១៩ ដល់គណៈអភិបាលរាជធានី-ខេត្ត ឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ដោយផ្អែកតាមតម្រូវការជាក់ស្តែង។

ទី៩-ក្រសួង-ស្ថាប័នសាធារណៈ, វិស័យឯកជន ព្រមទាំងបុគ្គលឯកជន ត្រូវបានលើកទឹកចិត្តក្នុងការប្រើប្រាស់ឧបករណ៍តេស្តរហ័សរកមេរោគកូវីដ-១៩ នៅក្នុងអំឡុងពេលនៃយុទ្ធនាការនេះ ដើម្បីជាវិធានការបង្ការក៏ដូចជាការស្វែងរកអ្នកវិជ្ជមានមេរោគកូវីដ-១៩ ដោយផ្អែកតាមអភិក្រម **"រកឃើញឆាប់រហ័ស, គ្រប់គ្រងបានលឿន, និងកាត់ផ្តាច់ខ្សែច្រវាក់ការឆ្លងរាលដាលបានទាន់ពេល"** សំដៅរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ទី១០-គណៈអភិបាលរាជធានី-ខេត្ត និងយន្តការដែលមានការពាក់ព័ន្ធ ត្រូវបង្កើនកិច្ចសហការគ្នា ដើម្បីដាក់ចេញរួមគ្នានូវវិធានការចាំបាច់នានាដែលត្រូវអនុវត្តក្នុងភូមិសាស្ត្ររាជធានី-ខេត្ត ដែលមានព្រំប្រទល់ជាប់គ្នាសំដៅគ្រប់គ្រងតំបន់ដែលមានការផ្ទុះឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេស មេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) ក៏ដូចជា ដើម្បីបង្ការការឆ្លងរាលដាលនៃជំងឺនេះក្នុងភូមិសាស្ត្រដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន។

ទី១១-យោងតាមការចាំបាច់នៃសភាពការណ៍ជាក់ស្តែងនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងភូមិសាស្ត្ររបស់ខ្លួន គណៈអភិបាលរាជធានី-ខេត្ត អាចសម្រេចបន្តការអនុវត្តវិធានការទាំងនេះ ក្នុងភូមិសាស្ត្ររបស់ខ្លួន និងដោយអនុលោមតាមអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ និងអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល។

ទទួលបានសារាចរនេះ គ្រប់ក្រសួង-ស្ថាប័ន គណៈអភិបាលរាជធានី-ខេត្ត និងយន្តការដែលមានការពាក់ព័ន្ធផ្សេងទៀត ត្រូវផ្សព្វផ្សាយនិងអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃច័ន្ទ ២រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ